www.khmerpostusa.com
សារព័ត៌មាន ខ្មែរផុស ស.រ.អា
KhmerPost USA
Lowell - Lynn - Revere - MA * Providence - Cranston - RI

Free Copies
Vol. 13. Issue #296
July 13Th, 2020
Office: 978-677-7163
Direct: 978-656-8141
Email:Khmerpostusa@gmail.com

## ព័ត៌មានសំខាន់ៗខាងក្នុង...

ឌុណល ត្រម បញ្ចេញកន្ទុយជាមេដឹកនាំ

សូមអាននៅទំព័រទី ០៥



"កូវីដ ១៩" បានផ្ទុះឡើងសារជាថ្មីបន្ទាប់ពី....

សូមអាននៅទំព័រទី ០៧



"អ្នកមាន និងអ្នកក្រ"នៅកម្ពុជា

សូមអាននៅទំព័រទី ១០



# ការស្ទង់មតិពីការបោះឆ្នោតប្រធានាធិបតីនៅខែវិច្ឆិកា២០២០



ចូបាយឌិន



ឌុណល ត្រម

ដោយ ពិន សំខុន

នៅសល់តែ១ខែប៉ុណ្ណោះ ដែលបេក្ខជន ឌុណល ត្រាំ នឹងបេក្ខជន ជោ បាយដិន ត្រូវធ្វើសន្និបាទនៅចំពោះមុខដំណាងសមាជិករបស់ខ្លួន ដើម្បីប្រកាសជាសាធារណថា"គណបក្សសាធារណរដ្ឋ"នឹង"គណបក្សប្រជាធិបតេយ្យ"មានគូរប្រជែងសម្រាប់កាបោះឆ្នោតសាកល ថ្ងៃអង្គារទី ៣វិច្ឆិកា ២០២០ ខាងមុខនេះហើយ។

គណបក្សសាធារណរដ្ឋបានសម្រេចយកលោក ឌុណល ត្រាំ បច្ចុប្បន្នជាប្រធានាធិបតី, ជាបេក្ខជនប្រធានាធិបតីអណត្តិថ្មី"អមដោយលោក ម៉ាយ ផេន ជាបេក្ខជនអនុប្រធានាធិបតីជាបន្តរទៅទៀត, សន្និសិទជាតិដើម្បីតែងតាំងបេក្ខជន នឹងធ្វើនៅ Nort Carolina ដែលថ្ងៃពិតប្រាកដមិនទាន់ប្រកាសជាសាធារណនៅឡើយទេ ដោយសារវិបត្តិកូវីដ១៩។

ខាងដំណាងឱ្យ"គណបក្សប្រជាធិបតេយ្យនឹងប្រកាសថាលោក ជោ បាយដិន ជាបេក្ខជនប្រធានាធិបតីផ្លូវការ ហើយដែលបេក្ខជនអនុប្រធានាធិបតី ក៏ត្រូវតែបង្ហាញនៅពេលសន្និបាទនោះជាចាំបាច់ដែរ សន្និសិទជាតិដើម្បីតែងតាំងបេក្ខជនប្រធានាធិបតីនៃគណបក្សប្រជាធិបតេយ្យនឹងប្រព្រឹត្តទៅនៅ Milvaukee Visconsen Center ថ្ងៃទី១៧-២០ សីហា២០២០។

ការស្ទង់មតិប្រជាពលរដ្ឋ បានផ្តល់ឱ្យ ជោ បាយដិន មានប្រៀប ២៤៨ដំណាង លើ ឌុណល ត្រាំ ដោយទទួលលទ្ធផលតែ ១៨៨ដំណាង ក៏ប៉ុន្តែនៅមានអ្នកមិនទាន់ច្បាស់លាស់ថា សម្រេចយកបេក្ខជនណាមួយនៅឡើយ មានដល់ទៅ ១០២ដំណាង, ដូច្នេះមិនទាន់មានន័យថា ជោ បាយដិន នឹងឈ្នះឆ្នោតនៅឡើយទេ។



មេធាវី លុយ ហាស្កែល LAW OFFICE OF LOUIS S. HASKELL
Excellent Service Since 1987
សេវាកម្មជាទីគាប់ចិត្តចាប់តាំងពីឆ្នាំ 1987
គ្រោះថ្នាក់ចរាចររថយន្តធុនតូច, រថយន្តធុនធំ និងម៉ូតូ • អន្តោប្រវេសន៍
ធ្វើពន្ធ • ការក្ស័យធន • គ្រោះថ្នាក់រអិលដួល • ឆ្កែខាំ
ដំណោះស្រាយ និងការពារបញ្ហាពន្ធដា
សូមអរគុណចំពោះការបន្តទុកចិត្តរបស់លោកអ្នកមកលើការិយាល័យមេធាវីយើងខ្ញុំ ក្នុងការដោះស្រាយបញ្ហាផ្នែកច្បាប់ និងពន្ធដារជូនលោកអ្នក ។ យើងខ្ញុំរំពឹងថា នឹងបានបម្រើលោកអ្នកយ៉ាងល្អនាពេលអនាគត។
បុគ្គលិកយើងខ្ញុំនិយាយភាសាខ្មែរ
Auto, Truck and Motorcycle Accidents
Immigration • Tax • Bankruptcy
Slip & Fall • Dog Bite
Tax Resolution & Defense
Thank you for your continued confidence
In our office to handle your legal and tax matters.
We look forward to serving you well into the future.
LAW OFFICE OF LOUIS S. HASKELL * 16 PINE STREET * LOWELL, MA * (978) 459-8359
16 Pine Street • Lowell, MA • 978-459-8359 • www.attorneyhaskell.com

# អាមេរិកដាក់ទណ្ឌកម្មឧកញ៉ា ទ្រី ភាព, លោក គន់ គីម និងក្រុមគ្រួសារ

ក្រសួងហិរញ្ញវត្ថុសហរដ្ឋអាមេរិក នៅថ្ងៃចន្ទ ទី៩ ខែធ្នូ បានដាក់ទណ្ឌកម្មលើលោក គន់ គីម និងឧកញ៉ា ទ្រី ភាព និងក្រុមគ្រួសារ ដោយចោទប្រកាន់ថា បានប្រព្រឹត្តអំពើពុករលួយ។

លោក គន់ គីម ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវបានសហរដ្ឋអាមេរិចដាក់ទណ្ឌកម្មក្រោមការចោទប្រកាន់ថា ជាប់ពាក់ព័ន្ធដោយផ្ទាល់ឬដោយប្រយោលក្នុងអំពើពុករលួយ។ នេះបើយោងតាមសេចក្តីថ្លែងការណ៍របស់ក្រសួងហិរញ្ញវត្ថុអាមេរិក។

ក្រសួងហិរញ្ញវត្ថុអាមេរិក បានចោទប្រកាន់ថា លោក គន់ គីម គឺជា "អ្នកជួយក្នុងការអភិវឌ្ឍនៅខេត្តកោះកុង និងបានទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុយ៉ាងច្រើនពីទំនាក់ទំនងរបស់គាត់ ជាមួយក្រុមហ៊ុនរដ្ឋមួយរបស់សាធារណរដ្ឋប្រជាមានិតចិន"។

សេចក្តីថ្លែងការណ៍នោះ បានបន្តថា លោក គន់ គីម "បានប្រើទាហានរបស់កងយោធពលខេមរភូមិន្ទ ដើម្បីបំភិតបំភ័យបំផ្លិចបំផ្លាញ និងទន្ទ្រានយកដី ដែលចង់បានដោយក្រុមហ៊ុនមួយគ្រប់គ្រងដោយសាធារណរដ្ឋប្រជាមានិតចិន"។

ក្រសួងហិរញ្ញវត្ថុអាមេរិកក៏បានដាក់ទណ្ឌកម្មប្រឆាំងនឹងសមាជិកគ្រួសារ៣នាក់ផ្សេងទៀតរបស់លោក គន់ គីម និងក្រុមហ៊ុនចំនួន៥ផ្សេងទៀត ដែលស្ថិតក្រោមការគ្រប់គ្រងរបស់បុគ្គលទាំងនេះ ដោយផ្ទាល់ ឬដោយប្រយោល។



គន់ គីម



ទ្រី ភាព

ជាមួយគ្នានេះដែរ ក្រសួងហិរញ្ញវត្ថុអាមេរិកក៏បានចោទប្រកាន់លោកឧកញ៉ា ទ្រី ភាព ពីបទចូលរួមដោយផ្ទាល់ឬដោយប្រយោលក្នុងអំពើពុករលួយ តាមរយៈការកាប់ឈើខុសច្បាប់ទ្រង់ទ្រាយធំ ដោយមានការឃុបឃិតគ្នាជាមួយមន្ត្រីកម្ពុជា។

ក្រុមហ៊ុនចំនួន១១ដែលចុះបញ្ជីក្រោមឈ្មោះឧកញ៉ា ទ្រី ភាព ក៏ត្រូវបានអាមេរិកដាក់ទណ្ឌកម្មផងដែរ។

បន្ទាប់ពីទទួលរងទណ្ឌកម្មហើយនោះ ក្រសួងហិរញ្ញវត្ថុអាមេរិក បាននិយាយថា រាល់ទ្រព្យសម្បត្តិនិងផលប្រយោជន៍របស់បុគ្គលនិងអង្គភាពដែលមានឈ្មោះខាងលើនៅអាមេរិក ឬស្ថិតក្រោមការគ្រប់គ្រងដោយជនជាតិអាមេរិក គឺត្រូវបានបង្កក ហើយត្រូវតែរាយការណ៍ទៅការិយាល័យត្រួតពិនិត្យទ្រព្យសម្បត្តិបរទេស។

លោក គន់ គីម មិនបានលើកទូរស័ព្ទទេ នៅថ្ងៃអង្គារ ទី១០ ខែធ្នូនេះ ខណៈដែលឧកញ៉ា ទ្រី ភាព មិនអាចទាក់ទងបានទេ។

លោក ផៃ ស៊ីផាន អ្នកនាំពាក្យរដ្ឋាភិបាលកម្ពុជាបាននិយាយថា ទណ្ឌកម្មនេះ "ជាការគួរឱ្យភ្ញាក់ផ្អើល" ហើយបានហៅទង្វើនេះជា "លក្ខណៈឯកតោភាគី" ពីក្រសួងហិរញ្ញវត្ថុសហរដ្ឋអាមេរិក។

លោក ផៃ ស៊ីផាន បាននិយាយដូច្នេះថា "នៅក្នុងកាតព្វកិច្ចរបស់រាជរដ្ឋាភិបាល គឺតម្រូវតាមច្បាប់ក្នុងការស្វែងរកការពិត និងដោះបន្ទុកក្នុងកិច្ចការពារប្រកបដោយយុត្តិធម៌ និងសុចរិតភាព សម្រាប់ប្រជាពលរដ្ឋខ្មែរនោះ ដែលលោកទទួលរងការចោទប្រកាន់នេះ"។

លោក ផៃ ស៊ីផាន បាននិយាយថា ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងអាមេរិក មិនមានអ្វីប៉ះពាល់នោះឡើយ គឺនៅតែបន្តក្នុង "ភាពស្វាហាប់ និងបរិបទគោរពគ្នាទៅវិញទៅមក ក្នុងន័យប្រជាជាតិអធិបតេយ្យ"។

ចំណែកឯក្រសួងការបរទេសវិញ បាននិយាយថា ទណ្ឌកម្មនេះគឺជា "ការវាយប្រហារប្រឆាំងនឹងកិច្ចខិតខំប្រឹងប្រែង ដើម្បីស្តារទំនុកចិត្តនិងភាពជឿជាក់រវាងកម្ពុជានិងសហរដ្ឋអាមេរិក តាមរយៈការផ្ញើសារទៅវិញទៅមក នាពេលថ្មីៗនេះ" រវាងនាយករដ្ឋមន្ត្រីសម្តេច ហ៊ុន សែន និងលោក ដូណាល់ ត្រាំ។

ដោយ ខេបូណូមីស

# សម្តេចតេជោ ហ៊ុន សែន: មន្ត្រីខិលខូចយកដីរដ្ឋ និងដីប្រជាពលរដ្ឋនឹងត្រូវទទួលទោសដ៏ធ្ងន់ធ្ងរ

ភ្នំពេញ : សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានព្រមានធ្ងន់ៗជាថ្មីថា មន្ត្រីរាជការដែលខិចលខូចឃុបឃិតគ្នាយកដីរដ្ឋ ឬដីរបស់ប្រជាពលរដ្ឋ និងរិះរកល្បិចធ្វើបាបប្រជាពលរដ្ឋនឹងត្រូវទទួលទោសធ្ងន់ធ្ងរបំផុត ហើយនឹងឈានទៅបណ្តេញចេញពីគណបក្សតែម្តង។

ការព្រមានធ្ងន់ៗរបស់សម្តេចតេជោ ហ៊ុន សែន បានធ្វើឡើងនៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី នាព្រឹកថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០នេះ។ ក្នុងកិច្ចប្រជុំនេះ សម្តេចតេជោ ហ៊ុន សែន បានលើកឡើងពីវិវាទដីធ្លីនៅស្រុកគាស់ក្រឡ ខេត្តបាត់ដំបង រវាងឧកញ៉ា សង ថន និងប្រជាពលរដ្ឋ។

សម្តេចតេជោ ហ៊ុន សែន បានគូសបញ្ជាក់ថា ជម្លោះដីធ្លីនេះគឺមានការឃុបឃិតរវាងមន្ត្រី និងលោកឧកញ៉ា សង ថន ដោយឃុបឃិតយកដីរបស់រដ្ឋ ហើយបែរជាបន្លំធ្វើឯកសារថាដីនោះជាដីស្របច្បាប់របស់ឧកញ៉ា ហើយកាត់ឆ្វៀលជូនប្រជាពលរដ្ឋទៅវិញ។

សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា ដើម្បីដោះស្រាយវិវាទដីធ្លីនេះ សម្តេចបានបញ្ជូនទៅក្រសួងយុត្តិធម៌ ក្រុមមេធាវីរបស់សម្តេច ព្រមទាំងអង្គភាពប្រឆាំងអំពើពុករលួយផងដែរ ដើម្បីស៊ើបអង្កេតលើរឿងនេះ។ ក្នុងកិច្ចប្រជុំ



នាព្រឹកមិញនេះ សម្តេចតេជោ បានបញ្ជាទៅលោកទេសរដ្ឋមន្ត្រី ឱម យ៉ិនទៀង ប្រធានអង្គភាពប្រឆាំងអំពើពុករលួយរៀបចំឯកសារពាក់ព័ន្ធលើវិវាទនេះដាក់ជូនគណៈរដ្ឋមន្ត្រីថែមទៀតផង។

ទន្ទឹមនឹងការលើកពីវិវាទដីធ្លីនេះ សម្តេចតេជោ ហ៊ុន សែន ក៏បានឆ្លៀតបញ្ជាក់ថា បញ្ហាដីធ្លីនេះដល់ពេលត្រូវជម្រះ និងត្រូវវះកាត់មន្ត្រីដែលខិលខូចហើយ។ សម្តេចតេជោ បានថ្លែងបញ្ជាក់យ៉ាងដូច្នេះថា "ចំពោះមន្ត្រីខិលខូច ដែលឃុបឃិតគ្នាយកដីរដ្ឋ និងយកដីប្រជាពលរដ្ឋ ហើយរិះរកកលល្បិចនិងវិធីផ្សេងៗធ្វើបាបប្រជាពលរដ្ឋវិញ ដើម្បីខ្លួនបានកាន់កាប់ដីធ្លីស្របច្បាប់គឺនឹងទទួលទោសដ៏ធ្ងន់ធ្ងរបំផុត ហើយនឹងឈានទៅបណ្តេញចេញពីគណបក្សតែម្តង។ ចំពោះប្លង់រឹងដែលបានធ្វើដោយអំពើឃុបឃិតទុច្ចរិតគឺនឹងរំលាយចោលវិញ។

សូមបញ្ជាក់ថា វិវាទដីធ្លីនៅស្រុកគាស់ក្រឡរវាងឧកញ៉ា សង ថន និងប្រជាពលរដ្ឋ បាន



ក្លាយទៅជាព្រឹត្តិការណ៍កក្រើក និងចាប់អារម្មណ៍ខ្លាំងក្នុងមជ្ឈដ្ឋានប្រជាពលរដ្ឋខ្មែរ។ វិវាទដីធ្លីនេះ នាំឱ្យសម្តេចតេជោ ហ៊ុន សែន សម្រេចបញ្ចប់តំណែងអភិបាលស្រុកគាស់ក្រឡលោក ម៉ៅ សុចាន់។

ជាមួយគ្នានេះ លោកឧកញ៉ា សង ថន និងអភិបាលរងខេត្តបាត់ដំបងម្នាក់ គឺលោក វ៉ាហ្វាត់ ត្រូវបានអង្គភាពប្រឆាំងអំពើពុករលួយហៅមកសួរនាំផងដែរ។

# ប្រជាធិបតេយ្យនៅអាមេរិក

ដោយ ពិន សំខុន

ការបោះឆ្នោតប្រធានាធិបតីអាមេរិកកាំងនឹងប្រព្រឹត្តទៅនៅខែវិច្ឆិកា២០២០ខាងមុខ តែវិធីសាស្ត្រនៃការបោះឆ្នោតនៅមិនទាន់ប្រាកដប្រជានៅឡើយទេ ដោយសារតែមេរោគ"កូវីដ ១៩" នៅតែកើនខ្ពស់នៅឡើយ សម្រាប់រដ្ឋមួយចំនួន។ រីឯរដ្ឋខ្លះទៀតនោះ ក៏បានធូរស្បើយ តែក៏នៅមិនទាន់ឱ្យបើកទាំងស្រុងនៅឡើយទេ។ ក្នុងខណៈដែលគេមិនទាន់ដឹងថា ការបោះឆ្នោតនឹងធ្វើទៅបានរបៀបណានោះ គេដឹងថានឹងមានបេក្ខជន២រូបនឹងចេញមកប្រកួតគ្នា គឺ១ លោកប្រធានាធិបតិបច្ចុប្បន្ន ឌុណល ត្រាំ ជាបេក្ខជនខាង"គណបក្សសាធារណៈរដ្ឋ" នឹងលោក ជោ បាយដិន ជាបេក្ខជនគណបក្សប្រជាធិបតេយ្យនឹងជាអតីតអនុប្រធានាធិបតីនៃប្រធានាធិបតី បារ៉ាក់ អូបាម៉ា ផងដែរ។

លោក ត្រាំ នៅតែបន្តធ្វើការឃោសនាបោះឆ្នោតនៅតាមរដ្ឋនានាជាមួយនឹងសមាជិកលោករាប់ពាន់នាក់ ដោយមានការប្រុងប្រយ័ត្នចំពោះមេរោគ"កូវិដ១៩"តិចតួច ដែលជាហេតុធ្វើឱ្យមេរោគនេះឆ្លងរាលដាលយ៉ាងសន្ធោរឡើងវិញនៅតាមរដ្ឋដែលមានចៅហ្វាយរដ្ឋ ជាគណបក្សសាធារណរដ្ឋ មានរដ្ឋតិចសាស ឬ រដ្ឋកាលីហ្វ័ញ៉ា ឬ រដ្ឋហ្វ្លរីដា ជាដើម។ ចុងក្រោយនេះប្រធានបទដែលធ្វើឱ្យប្រជាប្រិយភាពលោកត្រាំ ធ្លាក់ចុះមាន២ធំៗ គឺចំណាត់ការនឹងសម្ដីប្រកាន់ពូជសាសន៏ ដែលបណ្ដាលឱ្យមានបាតុកម្មពេញប្រទេសនឹងពេញពិភពលោក រហូតដល់ថ្ងៃនេះ ហើយនឹងការខ្វះចំណាត់ការប្រសិទ្ធិភាពដើម្បីទប់ស្កាត់ការរាតត្បាតរបស់មេរោគ"កូវីដ១៩"ដែលធ្វើឱ្យសហរដ្ឋអាមេរិកឋិតនៅចំណាត់ថ្នាក់ទី១ ក្នុងពិភពលោកនៃការឆ្លងមេរោគ"កូរ៉ូណា"សារជាថ្មី។ ថ្វីត្បិតតែស្ថិតនៅ១៤ពិន្ទុ ពីក្រោយ ជោ បាយដិន ក្នុងការស្ទង់មតិទូទាំងប្រទេសក៏ដោយក្រុមគាំទ្រលោក ត្រាំ នៅតែសង្ឃឹមថា លោក ត្រាំ នៅមិនទាន់បញ្ចេញល្បិច សម្រាប់យកឈ្នះនៅឡើយទេ នឹងថា ក្រុមនយោបាយលោក ជោ បាយដិន គឺជា"មនោគមន៍វិជ្ជាកុម្មុយនិស្ត"មិនត្រូវគ្នានឹងប្រទេសសេរីនៃសហរដ្ឋអាមេរិកនោះទេ។

នៅសល់តែ៤ខែតែប៉ុណ្ណោះ ដែលលោក ឌុណល ត្រាំ ត្រូវស្តារប្រជាប្រិយភាពរបស់លោកឡើងវិញជាប្រញាប់ ប៉ុន្តែលោកទើបតែនឹងត្រូវ

តទៅទំព័រទី


នរណានឹងក្លាយជាបេក្ខជនអនុប្រធានាធិបតី




ប្រធានាធិបតី ឌុណល ត្រម




មណ្ឌលពិនិត្យសុខភាពលីន
Lynn Primary Care Center
លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.
Sokharith Mey, M.D.
ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី
Now Accepting New Patients
អាស័យដ្ឋាន
280 Union Street, Unit 402 • Lynn, MA 01901 • (781) 780-7755
ទទួលយកម៉ាសហែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

LYNN PRIMARY CARE CENTER
មណ្ឌលពិនិត្យសុខភាពលីន

ជំងឺទូទៅ
Family Medicine
សុខភាពផ្លូវចិត្ត
Behavioral Health
We Accept MassHealth, Medicare
and Other Health Insurances
Our Staff Speaks Khmer

# មណ្ឌលពិនិត្យសុខភាពឡូវែល

## Lowell Primary Care Center

លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, **M.D.**
**Sokharith Mey, M.D.**

លោក ចាន់ ទូច , **C.N.P.**
**Chhan Touch, C.N.P.**





ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី
**Now Accepting New Patients**

ជំងឺទូទៅ
***Family Medicine***

&

សុខភាពផ្លូវចិត្ត
***Behavioral Health***

អាស័យដ្ឋាន

**1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992**

ទទួលយកម៉ាសហ៊ើល, មេឌីឃែ និងធានារ៉ាប់រងសខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer • Plenty of Free Parking

# ដណាល ត្រម បញ្ចេញកន្ទុយជាមេដឹកនាំផ្តាច់ការ

ដោយ ពិន ខុន

ព្រឹត្តិការណ៍ដែលបណ្តាលឱ្យបាត់បង់ជីវិតជនស្បែកខ្មៅម្នាក់ឈ្មោះ ផច ហ្លួយ អាយុ ៤៦ ឆ្នាំ កាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ ដោយការចាប់ចងរបស់ក្រុមប៉ូលីសក្រុងមីណេរអាប៉ូលី បានធ្វើឱ្យមានប្រតិកម្មបះបោរ ពីបណ្តាជនភាគច្រើនជនស្បែកខ្មៅទូទាំងប្រទេស ដោយគេបានឃើញរូបបង្ហោះតាមប្រព័ន្ធហ្វេសប៊ុកបុរសហ្លួយបានត្រូវក្រុមប៉ូលីសផ្តួល ហើយយកជង្គង់សង្កាត់ក ៧នាទី រហូតដល់ដាច់ដង្ហើមស្លាប់ បន្ទាប់ពីហ្លួយស្រែកថា "ខ្ញុំដកដង្ហើមមិនរួចទេ..." ។ បាតុកម្មអហិង្សាបានផ្ទុះឡើងភ្លាមនៅច្រើនទីក្រុង ប្រឆាំងនឹងអាកប្បកិរិយាព្រៃផ្សៃរបស់ប៉ូលិស ដែលច្រើនតែប្រើកម្លាំងហួសហេតុទៅលើជនអាមេរិកាំងស្បែកខ្មៅ បន្តិចក្រោយមកក៏លេចចេញបាតុកម្មមួយក្រុមទៀត ប្រើអំពើហិង្សាវាយកញ្ចក់ហាងតាមផ្លូវចូលលួចយកទំនិញក្នុងហាង វាយកំទេចរថយន្តតាមដងផ្លូវនៅក្រុងជាច្រើន។

លោកប្រធានាធិបតី ឌុណាល ត្រម បានខឹងសម្បានឹងការខូចខាតរបស់អ្នករកស៊ីជាខ្លាំង ហើយក៏មិនពេញចិត្តបាតុកម្មរបស់ជនស្បែកខ្មៅដែរ ដែលមិនត្រឹមតែប្រមូលផ្តុំគ្នា នាទីក្រុងធំជាច្រើន ដូចជានៅតិកសាស ហ្វតវទ ឡូសអងជើឡេស ហ្វេនិច តែប៉ុណ្ណោះទេ ថែមទាំងធ្វើបាតុកម្មនៅមុខសេដ្ឋវិមានទៀតផង តែនៅទីនោះពុំមានបាតុកម្មហិង្សាទេ ។ លោកបានចេញបញ្ជាអោយកងទ័ពសហព័ន្ធចេញប្រតិបត្តិការតាមរដ្ឋណា ដែលមិនស្តាប់បង្គាប់ថែមទៀត ។ ព្រឹកថ្ងៃទី៩ ខែមិថុនា លោកត្រាំ ស្រាប់តែនឹកចង់ចេញទៅថតរូប នៅមុខវិហារ "សេងជន" ស្ថិតនៅក្បែរ"សេដ្ឋវិមាន" លោកបានប្រើប៉ូលិស និងទាហានអោយទៅវាយកំចាត់បាតុករយ៉ាងចាស់ដៃ ដើម្បីបើកផ្លូវអោយលោកធ្វើដំណើរដោយជើងទៅកាន់ព្រះវិហារនោះ ធ្វើអោយរបួសបាតុករអហិង្សាជាច្រើន និងអ្នកសារព័ត៌មានផង ។ អាចារ្យម្ចាស់នៃព្រះវិហារថ្លែងថា "លោក ត្រម បានបង្ហាញខ្លួននៅទីដែលមិនមានការអនុញ្ញាត្តិ ហើយអានគម្ពីរព្រះគ្រីស្តដែលលោកមិនបានជឿថែមទៀត..." ។

ថ្វីត្បិតតែប៉ូលិសម្នាក់ដែលធ្វើឱ្យហ្លួយស្លាប់ និង៣នាក់ទៀតជាអ្នកសមគំនិតត្រូវបានបណ្តេញចេញ ហើយតុលាការបានចោទប្រកាន់ពីបទសម្លាប់មនុស្ស ក៏បាតុកម្មមិនបានស្រកបាក់កំហឹងនោះទេ ដោយសារបទបញ្ហា និងសារជាច្រើន



លោកប្រធានាធិបតី ឌុណាល ត្រម

របស់ប្រធានាធិបតី ត្រម បង្ហាញនូវការប្រកាន់ពូជសាសន៍មិនឈប់ឈរ ដែលប្រៀបបានទៅនឹង"យកសាំងទៅពន្លត់ភ្លើង" ដែលជាហេតុធ្វើឱ្យបាតុកម្មនេះ រិតតែរីករាលដាល រហូតដល់ពាសពេញសកលលោកប្រឆាំង និងនយោបាយ "ស្តាំផុត"របស់ប្រធានាធិបតី ត្រម ។

សមាជិកគណបក្សសាធារណៈរដ្ឋនៅសភាតំណាងរាស្ត្រ និងព្រឹទ្ធសភា នៅការពារប្រធានាធិបតីនៃគណបក្សរបស់ខ្លួនយ៉ាងស្ងៀមស្ងាត់ផ្ទុយគ្នាទៅនឹងទង្វើខាងគណបក្សប្រជាធិបតេយ្យ ក៏ប៉ុន្តែអតីតរដ្ឋលេខាធិការលោកប្រធានាធិបតី ប៊ូស លោក ខលីង ផូវិល, លោកស្រី "វាយស៍ លោកអតីតបេក្ខជនប្រធានាធិបតី មីត "រមនីយ មិនបាននៅស្ងៀមដូចសមមិត្តខ្លួនទេ ទាំងអស់ជាវរជនខាងគណបក្សសាធារណរដ្ឋបានប្រកាសថា "ត្រម ជាមនុស្សគ្រោះថ្នាក់ ហើយបានរំលោភរដ្ឋធម្មនុញ្ញមាត្រា១"និយាយរួចក៏ប្រកាសទៅគាំទ្របេក្ខភាពប្រធានាធិបតីក្រោយ លោក ជោ បាយដិន បានទទួលប្រជាប្រិយភាព ១៤% លើសលោក ត្រម ទៅហើយនាពេលនេះ។

## ខ្មែរនៅអាមេរិកអុំទូកទល់មុខគ្នា

ឱកាសបោះឆ្នោតសកលសម្រាប់ជ្រើសរើសប្រធានាធិបតីនឹងមកដល់ នាខែវិច្ឆិកា ២០២០ ខាងមុខនេះហើយ គេមិនទាន់ដឹងថា សហរដ្ឋអាមេរិក នឹងប្តូរវិធីបោះឆ្នោត ដោតប្រធានាធិបតី ត្រម ក្នុងឱកាស "កូវីត១៩" នេះឬយ៉ាងណានោះទេ ប៉ុន្តែសហគមន៍ខ្មែរនៅអាមេរិក នេះកំពុងបែងចែកទស្សនៈគាំទ្របេក្ខជននយោបាយអាមេរិកាំងខុសៗគ្នា ដើម្បី"កេងយកអំណាចអាមេរិកាំងទៅជួយកម្ពុជា" ដែលមានការរំលោភស្មារតីនៃមាត្រាទី១ នៃរដ្ឋធម្មនុញ្ញដោយមេដឹកនាំខ្លួនដូចគ្នា ។ នៅឡុងប៊ិចជាសហគមន៍ខ្មែរធំទី១ គេបានប្រកួកគ្នាអោយគាំទ្របេក្ខជន ត្រម ចំណែកឯនៅឡូវែលវិញ ជាទីក្រុងសម្បូរសហគមន៍ខ្មែរធំទី២ ជាជំរុំគាំទ្រគណបក្សប្រជាធិបតេយ្យមានទាំងតំណាងរាស្ត្រខាងគណបក្សប្រជាធិបតេយ្យដើមកំណើតខ្មែរច្រើននាក់ផង នៅមិនទាន់ប្រកាសទំនោរចិត្តរបស់ខ្លួនដឹកនាំគាំទ្រខាងណាមួយនៅឡើយទេ ដែលពេលនេះគេហៅថា កំពុងតែ"ចាក់ខ្សែ" ។ពីកម្ពុជាមកគេកំពុងសើចចំអក"អ្នកអាមេរិក"ថានឹងមកជួយ "អ្នកស្រុកខ្មែរ"យ៉ាងម៉េចបាន បើគេ"អុំទូកទល់មុខគ្នា"យ៉ាងនេះ?

កូវីត១៩ ទើបតែនឹងធ្លាក់ស្រុតចុះបានបន្តិច នៅសល់អ្នកឆ្លងជម្ងឺប្រមាណ៨០នាក់ក្នុង ១ថ្ងៃ នឹងស្លាប់ប្រមាណ២០នាក់ ក្នុង១ថ្ងៃ ក្នុងសេចក្តីរាយការណ៍ពី "ប៊ូសស្តុន" តែមិនទាន់ធានាថា នឹងបើកទីក្រុង"ប៊ូស្តុន"ឬរដ្ឋ"ម៉ាសាឈូសេត"បានពេញលេញនៅឡើយទេ ។សភាសាធារណរដ្ឋ និង ឌុណាល ត្រម ទាមទារអោយចែកជំនួយ"ស្ទីមីឡឺស" អោយចំទិសដៅនៃអ្នកត្រូវការអោយជួយ"គឺពួកអ្នកមាន"ចំណែកឯសភាខាងប្រជាធិបតេយ្យធ្វើច្បាប់អោយជួយអ្នកក្រ និងអ្នកជំនួញខ្នាតតូចជាមុន ក្រុមទាំង ២ បានអូសបន្លាយ ពេលចែកចាយជំនួយឮថារហូតសល់ទៅពាក់កណ្តាលខែកក្កដាទៀតផង ។

សេចក្តីរាយការណ៍ព័ត៌មានបានបង្ហាញថា "តាំងពីពេលដែលលោក ត្រម បានចូលមកកាន់តំណែងនៅសេដ្ឋវិមានក្រុមលើកដំកើងពណ៌សម្បុរស្បែកសគគត ពួកណាស៊ី និងក្រុមឧត្តមភាពស្បែកសពីរក្រុមទៀត បានលេចចេញធ្វើសកម្មភាពដូចអតីតកាល "ដែលគេស្មានថា ស្លាប់បាត់បង់ទៅហើយនោះ" គួរឱ្យខ្លាច។ ជាមួយគ្នានោះក្រុមហិង្សាស្បែកខ្មៅតស៊ូប្រឆាំងនឹងក្រុមស្បែកសប្រកាន់សម្បុរស្បែកឈ្មោះAntifasc ក៏ផ្ទុះចេញមកដែរ ។ គឺក្រុមនោះហើយ ដែលថ្វីត្បិតតែការពារពួកគេ "បាតុករអហិង្សា" ស្បែកខ្មៅ តែប្រើហិង្សាមានវាយកំទេចហាងអ្នករកស៊ីសម្បត្តិសាធារណៈតាមផ្លូវ បង្ហាញកំហឹងទប់ទល់នឹងក្រុមលើកដំកើងសរស្បែកស ដែលលេច "កន្ទុយហិង្សា" គួរឱ្យគេសង្ស័យថា លាក់ខ្លួននៅក្នុងកងការពារ សន្តិសុខជាតិ ឥឡូវអាចនឹងកំពុងកាន់ដំណែងដ៏ខ្ពស់បំផុតនៅសហរដ្ឋអាមេរិកទៀតផង។

ប្រធានាធិបតីមុនៗ ទាំងពីរគណបក្សនយោបាយបានធានាសន្តិភាពរវាងក្រុមហិង្សាទាំងពីរខាងប្រកបដោយប្រសិទ្ធិភាព រហូតមកទល់ពេលនេះ ។ ហេតុនេះហើយ ដើម្បីបង្កើត "សន្តិភាពដែលបាត់បង់" នោះមកវិញ មានសមាជិកគណបក្សសាធារណៈរដ្ឋខាងប្រធានាធិបតី ត្រម កាន់តែច្រើនកាន់តែខ្ពង់ខ្ពស់ បានសម្រេចចិត្តទៅគាំទ្របេក្ខភាពគណបក្សផ្ទុយ គឺ ជោ បាដិន ជាស្មារតីទប់ស្កាត់ និងជួសជុលសន្តិភាពនោះនៅស្ថាប័នជាតិជាន់ខ្ពស់ នៅពេលដែលគេបានឃើញថា គ្រប់វិធានការក៏រិតជាតិ តែងតែបញ្ឆេះ "វិវាទប្រកាន់ពូជសាសន៍" មិនចេះឈប់។

តមកពីទំព័រទី ០៣

## ប្រជាធិបតេយ្យនៅអាមេរិក...

ក្តោងពីសមាជិកជាន់ខ្ពស់មួយចំនួនរាប់ទាំងលោក"ជន ប៉ុលតុន"អតីតទីប្រឹក្សាសន្តិសុខជាតិនៃគណបក្សរបស់លោកថា"លោកត្រាំជាមនុស្សដែលប្រកបដោយគ្រោះថ្នាក់ជាទីបំផុត"។ បន្ថែមពីនោះ នាឱកាសចុងក្រោយបង្អស់នេះ តុលាការកំពូលបានអនុញ្ញាត្តិឱ្យក្រុងញូយ៉ក បើកសំណុំរឿង "បង្ហាញឯកសារពន្ធនៃប្រាក់ចំណូល" កាលពីថ្ងៃទី៩ កក្កដា ដែលលោក ត្រាំ តែងតែលាក់បំបាំងនោះ មកវិញហើយ។

ចំណែកលោក ជោ បាដិន ជាគូប្រគួតយ៉ាងមានប្រៀប នៅមិនទាន់បង្ហាញបេក្ខភាពនៃអនុប្រធានាធិបតីរបស់លោកនៅឡើយទេ តែគេសង្ស័យថា បេក្ខជនឬបេក្ខនារីនោះនឹងបង្ហាញការភ្ញាក់ផ្អើលដល់ម្ចាស់ឆ្នោត គឺជាស្ត្រីភេទដែល

នឹងក្លាយជាស្ត្រីអនុប្រធានាធិបតីទី១ នៅសហរដ្ឋអាមេរិក, នឹងជាជនជាតិភាគតិចទៀត ដែលអាចគៀងគរសន្លឹកឆ្នោតពីស្ត្រីផង នឹងពីជនជាតិភាគតិច ដែលកំពុងតែរើបំរះ ពីគំនាបនយោបាយបច្ចុប្បន្ន, ខ្លះទៀតថាប្រហែលជា "មីសែល អូបា ម៉ា"ទៀតផង នោះទើបជារឿងអស្ចារ្យមែន។

ប្រជាពលរដ្ឋខ្មែរ-អាមេរីកាំង នៅឡុងប៊ិច - ឡូសអង់សឺឡេស បានចងក្រងគ្នាជាក្រុមដ៏សំខាន់មួយ ដើម្បីកាពារប្រធានាធិបតី ឌុណល ត្រាំ ឱ្យបានកាន់អំណាច៤ឆ្នាំ តទៅមុខទៀត ក៏ប៉ុន្តែខ្មែរ-អាមេរីកាំង នៅឡូវែល- គូណិកទីកិត -ភីឡាដែលហ្វៀ មានតិចតួចណាស់ ដែលបានយល់ស្របគ្នានេះ តែក្រុមចុងក្រោយនេះ មិនទាន់មានសកម្មភាពប្រជាធិបតេយ្យនៅឡើយទេ។ គេរង់ចាំមើល ដំណាងខ្មែរនៅសាលាក្រុងមានលោក វ៉ាស្នា នួន លោក សុខារី ចៅ នៅឡូវែល, លោក ហុង ណេត នៅទីក្រុងលីន, លោក "រ៉ាឌី មំម ជាដំណាងរដ្ឋនៅបូស្តុន តើមានការណែនាំអ្វីខ្លះ ពីរបៀបបោះឆ្នោតថ្មី ឬក៏បំណងជ្រើសរើសប្រធានាធិបតីណាមួយ ជាទីស្រឡាញ់របស់ពួកគេដែរឬទេ ? ប្រជាពលទំនងជាចង់ឃើញនឹងឮសម្លេងអស់លោកទាំងនោះ នាពេលនេះហើយដែរ ពីព្រោះចាប់តាំងពី៤-៥ខែ នៃ "បំរាមកូវីត១៩"ក៏ស្រាប់តែបាត់អស់លោកទាំងនោះ សូន្យឈឹងតែម្តង។

# តំបន់អភិរក្សសត្វស្លាប និងព្រៃលិចទឹក ក្នុងស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ នឹងក្លាយជាមណ្ឌលទេសចរណ៍ធម្មជាតិ

(ត្បូងឃ្មុំ)៖ "តំបន់អភិរក្សសត្វស្លាប និងព្រៃលិចទឹកក្នុងស្រុកក្រូចឆ្មារ នឹងក្លាយជាមណ្ឌលទេសចរណ៍ធម្មជាតិ"។ នេះជាគំនិតផ្តួចផ្តើមរបស់លោក ជា សុផា៉រា ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងារចុះមូលដ្ឋានខេត្តត្បូងឃ្មុំ។

លោកបណ្ឌិត ជាម ច័ន្ទសោភ័ណ អភិបាលខេត្តត្បូងឃ្មុំថ្លែងបែបនេះ នាព្រឹកថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០ ក្នុងឱកាសលោកបណ្ឌិត និងលោក ស៊ាក ឡេង ប្រធានក្រុមប្រឹក្សាខេត្ត រួមដំណើរដោយអភិបាលរងខេត្ត បានដឹកនាំក្រុមការងារមន្ទីរអង្គភាពជុំវិញខេត្ត អាជ្ញាធរមូលដ្ឋាន រួមនឹងមន្ត្រីពាក់ព័ន្ធជាច្រើនរូប ចុះពិនិត្យការដ្ឋានសាងសង់ទំនប់បង្ហៀរទឹក ព្រែកតាកុច និងបឹងកណ្តោរ រួមទាំងទីតាំងច្រាំងបាក់ (នៅខាងក្រោយគេហដ្ឋានសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន) ស្ថិតនៅក្នុងស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។

នាឱកាសនោះលោកបណ្ឌិត ជាម ច័ន្ទសោភ័ណ បានលើកឡើងថា ថ្វីត្បិតតែដំណាក់កាលនេះ ប្រទេសយើងកំពុងតែប្រយុទ្ធប្រឆាំងនឹងការរីករាលដាលជំងឺកូវីដ១៩មែន តែការងារអភិវឌ្ឍន៍នៅតែធ្វើបន្តឥតឈប់ឈរ។ ជាក់ស្តែងនៅថ្ងៃនេះ រដ្ឋបាលខេត្តត្បូងឃ្មុំ បានដឹកនាំកម្លាំងមន្ត្រីក្រោមឱវាទ មានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ខេត្ត រួមទាំងរដ្ឋបាលស្រុកក្រូចឆ្មារ និងអ្នកពាក់ព័ន្ធបានចុះពិនិត្យដោយផ្ទាល់ក្នុងតំបន់នេះ ក្នុងការកសាងឱ្យបានប្រសើរឡើងវិញ ហើយយើងទាំងអស់គ្នាត្រូវតែការពារឱ្យបានគង់វង្ស។



ជាមួយគ្នានោះលោកបណ្ឌិតអភិបាលខេត្តត្បូងឃ្មុំ ក៏បានអំពាវនាវដល់គ្រប់មជ្ឈដ្ឋានទាំងអស់ចូលរួមថែរក្សាទីតាំងទំនប់ទាំងនោះឱ្យបានល្អ ដោយរក្សាបានសត្វស្លាបធម្មជាតិ និងកន្លែងជម្រកត្រីពងកូន ព្រមទាំងជំរុញឱ្យពលរដ្ឋលើកកម្ពស់បរិស្ថានទុកសម្រាប់ជាគុណប្រយោជន៍ដល់សង្គមជាតិយើងទាំងអស់គ្នាក្នុងន័យដើម្បីស្តារ និងអភិរក្សតំបន់ដីសើមឱ្យបានប្រសើរឡើងវិញ ដើម្បីជាប្រភពសម្រាប់បង្កើតជម្រកមច្ឆាជាតិ និងជីវចម្រុះ។

លោកបណ្ឌិត ជាម ច័ន្ទសោភ័ណ បានបន្ថែមថា តាមចក្ខុវិស័យនឹងអភិវឌ្ឍន៍ប្រែក្លាយពីតំបន់ព្រៃរនាមទៅជាជំរកត្រីពងកូន និងតំបន់ដីសើមមួយនេះ ឱ្យក្លាយទៅជាកន្លែងអភិរក្សបរិស្ថាន

តទៅទំព័រទី ១១







We're OPEN
Lowell Primary Care Center
OPEN DURING COVID-19 PANDEMIC
Telehealth
Primary Care & Behavioral Health




មណ្ឌលពិនិត្យសុខភាពឡូវែល
បន្តបើកទ្វារបំរើសេវាសុខភាពជូនអ្នកជំងឺទាំងអស់ក្នុងសហគមន៍
ក្នុងកំឡុងពេលនៃការរីករាលដាលនៃជម្ងឺ COVID-19
តាមរយៈ Telehealth
សេវាផ្នែកពេទ្យគ្រួសារនិងសុខភាពផ្លូវចិត្ត
Call: (978) 455-7992

We're OPEN
Lynn Primary Care Center
OPEN DURING COVID-19 PANDEMIC
Telehealth
Primary Care & Behavioral Health




មណ្ឌលពិនិត្យសុខភាពលីន
បន្តបើកទ្វារបំរើសេវាសុខភាពជូនអ្នកជំងឺទាំងអស់ក្នុងសហគមន៍
ក្នុងកំឡុងពេលនៃការរីករាលដាលនៃជម្ងឺ COVID-19
តាមរយៈ Telehealth
សេវាផ្នែកពេទ្យគ្រួសារនិងសុខភាពផ្លូវចិត្ត
Call: (781) 780-7755

# “កូវិដ១៩”បានផ្ទុះឡើងសារជាថ្មីបន្ទាប់ពី“យូឡាយ៤”

ដោយ ពិន សំខុន

សហភាពអឺរ៉ុបបានបិទទ្វារចំពោះអាមេរិកាំង ដែលចង់ទៅប្រទេសណាមួយនៃសហភាពកាលពីចុងខែមិថុនា២០២០ ដោយសារអាមេរិក ជាសម្បុកនៃមេរោគឆ្លង“កៅរ៉ូណាវ៉ារីស” ដោយរាប់ទាំងប្រទេស“ប្រេស៊ីល”នឹងរុស្ស៊ីផងដែរ -នេះគឺនៅពេលដែលអាមេរិកកំពុងមានសង្ឃឹមថា “នឹងបើកប្រទេសឱ្យមានភាពប្រក្រតីឡើងវិញផង។ ប៉ុន្តែស្រាប់តែ១សប្តាហ៍បន្ទាប់ថ្ងៃបុណ្យ “July 4th.”រួច មេរោគឆ្លងនោះ ក៏បានផ្ទុះឡើងខ្ពស់ម្តងទៀត នៅរដ្ឋចំនួន៤០ ក្នុងនោះមានៈ រដ្ឋហ្វ្លរីដា, រដ្ឋតិចសាស់, រដ្ឋកាលីហ្វញ៉ា, រដ្ឋការ៉ូឡាយណា,មានទាំងរដ្ឋម៉ាសាឈូសិត... ។ល ។ នៅមានរដ្ឋប្រមាណ២០ទៀត ដែលនៅស្មើនឹងចុះខ្លះទៀតផង មានរដ្ឋញូយ៉ក ដែលធ្លាប់រងគ្រោះធ្ងន់ជាងគេ គេមិននឹកស្មានថាអាចធ្វើឱ្យចុះបានថែមទាំងចុះបានយ៉ាងប្រសើរទៀតផង ។

នៅរដ្ឋហ្វ្លរីដា នាថ្ងៃសៅរ៍មុននេះ មានករណីឆ្លងជម្ងឺហក់ឡើងចំនួន១៥២៩៩នាក់ តែក្នុង១ថ្ងៃ គឺជាចំនួនដ៏ច្រើនបំផុត ដែលតម្រូវឱ្យរដ្ឋហ្វ្លរីដាបិទក្រុមរបស់ខ្លួនសាជាថ្មី ដោយសារមនុស្សម្នានាំគ្នាទៅកំសាន្តនៅរមណីដ្ឋានមាត់សមុទ្រយ៉ាងកុះករ ដោយគ្មានការប្រុងប្រយ័ត្ន ។ នៅរដ្ឋតិចសាសក៏ដូចគ្នា គេបាននាំគ្នាចេញទៅកំសាន្តជួបជុំគ្នាគគ្រឹកគគ្រេង” នៅតំបន់នាទីក្រុងជិត៧នៅក្នុងរដ្ឋ ហើយត្រឡប់យកមកផ្ទះវិញ នូវមេរោគដែលចម្លងដល់ក្រុមគ្រួសារនឹងមិត្រភក្រ្តិ



ពិធីឃោសនារបស់លោក ឌុណល ត្រម មិនមានពាក់ម៉ាស់មុខទេ

របស់ខ្លួន ។

ខុសគ្នាពីរដ្ឋខាងលើ្ស នៅរដ្ឋម៉ាសាឈូសិត លោកចៅហ្វាយរដ្ឋបេគើ បានដាក់កងប៉ូលីសរាយនៅតាមរមណីយដ្ឋាន ដែលអាចមានទេសចរសម្រុកចូលនាឱកាស“បុណ្យយូឡាយហ្វ” គេមិនអនុញ្ញាត្តិឱ្យមនុស្សមកកំសាន្តនៅទីឆ្នេរសមុទ្រ ឬប្រជុំជនលើសចំនួនដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់នោះទេ គេបានបញ្ជាឱ្យមានការសុំទិដ្ឋការ“អនឡាញ”ជាមុន ហើយបង់ប្រាក់សំចត១២ដុល្លាក្នុងរថយន្តមួយ ដើម្បីឱ្យអាចចូលរមណីយដ្ឋានបាន ហើយត្រូវបញ្ជាក់ពីចំនួនមនុស្សថែមទៀត មុននឹងចេញដំណើរ។ ធ្វើប៉ុណ្ណឹងហើយ ក៏នៅតែកើនការចម្លងជម្ងឺបានខ្លះៗ តែមិនហួសហេតុទេ ហើយទីក្រុង នៅតែបន្តបើកតាមគម្រោងដល់ក៏រីត៣ ដែលអនុញ្ញាត្តិឱ្យភ្ញៀវចូលអង្គុយតុក្នុងភោជនីយដ្ឋានឡើងវិញបាន តែមិនទាន់ឱ្យជួបជុំគ្នាលើសពី១០នាក់ ជាពិធីបុណ្យអ្វីមួយបាននៅឡើយទេ ។

នៅឱកាសពីធីបុណ្យ“៤កក្កដា”អាមេរិកាំងគេទម្លាប់ជួបជុំគ្នា ស៊ីផឹក អបអរសាទរជាមួយមនុស្សជិតឆ្ងាយ ពេញមួយថ្ងៃ រហូតដល់គេបាញ់កាំជ្រួចពេលយប់ចប់រួចរាល់, តែឆ្នាំនេះ ក្រសួងសុខាភិបាលនឹងគណកម្មការ“កូវីដ១៩” បានចេញសេចក្តីប្រកាសឱ្យដំបូន្មានមិនឱ្យមានការជួបជុំគ្នាមានមនុស្សច្រើននោះទេ ហើយឱ្យប្រុងប្រៀបប្រយ័ត្នដោយពាក់របាំងមុខ ពេលចេញទៅកាន់ទីប្រជុំជនផង តែប្រជាពលរដ្ឋមិនបានស្តាប់បទបញ្ជានេះទេ ដោយរាប់ទាំងប្រធានាធិបតីនៃសហរដ្ឋអាមេរិក ឌុណល ត្រាំ ផង, លោកមិនដែលពាក់របាំងមុខនៅទីសាធារណៈ ជាគំរូនោះទេ ។ ដោយសារតែការផ្ទុះជម្ងឺរាតត្បាតឡើងវិញនោះ ទើបគេឃើញលោក ត្រាំពាក់របាំងមុខជាលើកដំបូងនៅទីសាធារណ កាលពីថ្ងៃអាទិត្យទី១២កន្លងទៅនេះ ។

សេចក្តីរាយការ ពីគណកម្មការ“កូវិដ១៩” បាននិយាយថា សហគមន៏ជនជាតិសាសន៏ដែលប៉ះពាល់ខ្លាំងជាងគេ គឺមិនមែនក្រុមស្បែកខ្មៅនោះទេ គឺជា“ក្រុមស្បានីស”ឯណោះសោះ ដែលប៉ះពាល់ខ្លាំងជាងគេ គឺមានរហូតដល់៧០% នៃអ្នកឆ្លងជម្ងឺកូវីដ១៩នោះរីឯសហគមន៏អាស៊ីមានតែ៧ភាគរយទេ ក្រុមស្បែកខ្មៅមាន១២% ។ គេបានសន្និដ្ឋានថា ជម្ងឺនេះរាតត្បាត នៅក្នុង

តទៅទំព័រទី ០៩

# ការទទួលទានទឹកដូងខ្ចីអាចជួយរំលាយអាហារ និងសម្រកទម្ងន់



ប៉ុន្មានឆ្នាំចុងក្រោយនេះ ទឹកដូងខ្ចីទទួលបានការពេញនិយមយ៉ាងខ្លាំងពីសំណាក់មនុស្សស្ទើរគ្រប់វ័យ ។ វាត្រូវបានគេនិយាយថាមានអត្ថប្រយោជន៏យ៉ាងច្រើនដល់សុខភាព រាប់ចាប់ពីផ្តល់ជាតិទឹកដែលបាត់បង់បង្កើនការរំលាយអាហារ និងជួយសម្រកទម្ងន់ជាដើម ។ ដោយមានកាឡូរីត្រឹម៥០ក្នុងមួយពែង ដូច្នេះគេមិនគួរមើលរំលងភេសជ្ជៈបង្កើនថាមពលពីធម្មជាតិនេះទេ ។ ខាងក្រោមនេះជាអត្ថប្រយោជន៏ផ្សេងទៀតដែលបានមកពីការទទួលទានទឹកដូង :

១-ផ្តល់អត្ថប្រយោជន៏ជាអាហារូបត្ថម្ភដល់រាងកាយ : ជាធម្មជាតិរបស់ទឹកដូងគឺមានសារធាតុកាបូអ៊ីដ្រាតក៏ដូចជា សារធាតុស្ករកម្រិតទាបខណៈ សារធាតុខ្លាញ់សេរី គឺមាន៩៩ភាគរយ ។វាមានតុល្យភាពធម្មជាតិនៃសូដ្យូម កាល់ស្យូម និងម៉ាញេស្យូម ។ លើសពីនេះទៀត ទឹកដូងផ្ទុកទៅដោយរ៉ែប៉ូតាស្យូមក្នុងបរិមាណដ៏ធំ ។ ប៉ូតាស្យូមមានប្រសិទ្ធភាពជួយរក្សាឱ្យដំណើរលោតរបស់បេះដូងមានភាពទៀងទាត់ និងត្រឹមត្រូវ ហើយ ក្នុងនាមជាភេសជ្ជៈបំពេញជាតិទឹកដែលបាត់បង់ទឹកដូងខ្ចី បានជួយឱ្យសាច់ដុំ បណ្តាសរសៃប្រសាទ និងតម្រងនោមមានដំណើរការល្អ ។

យោងតាមទិន្នន័យអាហារូបត្ថម្ភរបស់ក្រសួងកសិកម្មសហរដ្ឋអាមេរិកឱ្យដឹងថា ក្នុងទឹកដូងមួយផ្លែមានផ្ទុកសារធាតុរ៉ែប៉ូតាស្យូមប្រហែលជា៥១៥មីល្លីក្រាមពោលគឺប្រហែល២២ភាគរយ ច្រើនជាងចេកមួយផ្លែដែលមានប៉ូតាស្យូម៤២២មីល្លីក្រាម ។

២-ជួយពង្រឹងប្រព័ន្ធការពាររាងកាយ : ដោយវត្តមានអាស៊ីតឡូរិចនាំឱ្យការទទួលទានទឹកដូងអាចជួយពង្រឹងប្រព័ន្ធការពាររាងកាយដ្បិតអាស៊ីតឡូរិចមានកម្លាំងប្រឆាំងវីរុសបាក់តេរី និងពពួកផ្សិត ។ ជាមួយលក្ខណៈសម្បត្តិទាំងនេះនាំឱ្យការទទួលទានទឹកដូងគឺអាចជួយពង្រឹងដល់ប្រព័ន្ធភាពស៊ាំរបស់រាងកាយក៏ដូចការប្រយុទ្ធប្រឆាំងនឹងជំងឺប៉េស និងជំងឺគ្រុនក្តៅ ។

**៣-ជួយបង្គ្រប់ជាតិទឹកដែលបាត់បង់ :** ទឹកដូងមានសមត្ថភាពស្តារឡើងវិញនូវវត្ថុរាវរបស់រាងកាយដែលបាត់បង់ ។ រាប់សតវត្សរ៍មកហើយ វាត្រូវបានគេប្រើជាភេសជ្ជៈអ៊ូរ៉ាលីតធម្មជាតិ ។ ចូរបំភ្លេចចោលនូវបណ្តាភេសជ្ជៈ ប៉ូវកម្លាំងដែលផ្អែមដោយស្ករ ហើយជំនួសមកវិញនូវទឹកដូងខ្ចីដែលមានគុណប្រយោជន៏ជាអាហារូបត្ថម្ភដល់រាងកាយ ។ វាជាជម្រើសនៃភេសជ្ជៈធម្មជាតិដ៏សមស្របដែលអាចជំនួសបណ្តាភេសជ្ជៈមានកាឡូរីខ្ពស់ ។

ទឹកដូងខ្ចីផ្ទុកទៅដោយសារធាតុស្ករកើតពីធម្មជាតិក្នុងចំនួនមួយដែលរាងកាយងាយស្រួលក្នុងការស្រូបយក ។ អ្នកដែលមានជំងឺ រាករូស និងការខ្វះជាតិទឹកអាចផឹកទឹកដូង ខ្ចីបានដោយដាក់អំបិលតិចតួច ។

៤-ការពារប្រឆាំងនឹងការរលាកផ្លូវទឹកនោមៈ ដោយសារតែទឹកដូងគឺជាភេសជ្ជៈដែលបង្កើនការផលិតទឹកនោម ដូច្នេះវាជួយគ្រប់គ្រងលំហូរទឹកនោមដោយបង្កើនការបត់ជើងតូច ។ ដោយមូលហេតុនេះ នាំឱ្យវាក្លាយជាភ្នាក់ងារជួយសម្អាតផ្លូវទឹកនោមទប់ស្កាត់បាននូវការរលាក ។

# "ចក្ខុវិស័យ" ថ្វីត្បិត"កូវិដ១៩"សាហាវ តែពិភពលោកនឹងនៅតែប្តូរផ្លាស់

ដោយ ពិន សំខុន

ឡូវែល-ថ្ងៃទី២០មិថុនា២០២០

តើនឹងមានអ្វីប្តូរផ្លាស់នៅក្រោយកូវិដ ១៩?(ត)

១-បច្ចេកវិជ្ជាទំនើបបំផុត បានចូលមកដល់: លោកអ្នកមានចាំទេ! កាលពីចុងឆ្នាំ ២០១៩ គេនាំគ្នានិយាយពីការចូលមកដល់នៃគ្រឿង"អេឡិកត្រូនិកជំនាន់ទី៥-៥អ"ប្រព័ន្ធដែលផលិតចេញពី៥អនោះទៅហើយ វាមានអនុភាព, ប្រសិទ្ធិភាពនឹងសុវត្ថិភាព២០០ដងលើសពីសម្ភារៈដែលយើងកំពុងប្រើប្រាស់សព្វថ្ងៃនេះ មានទូរស័ព្ទដៃ មានទូរទស្សន៍មានសេវា "វ៉ាយហ្វាយ" មានសេវ៉ាទំនាក់ទំនងជិតឆ្ងាយ... ។ល។ ដែលជាប្រព័ន្ធ"ជំនាន់ទី៤-៤អ"- វានឹងត្រូវគេបោះបង់ចោលនៅពេលដែល ៥អ នឹងចូលមកដល់ជំនួស ៤អ នោះជាមិនខាន។

**ដូច្នេះ តើ ៥អ នឹងមកដល់នៅពេលណា?** វាបានមកដល់រួចទៅហើយ! ជាថ្មីម្តងទៀត វាមានដើមកំណើតនៅប្រទេសចិន ហើយចិនកំពុងតែបញ្ចេញទូរស័ព្ទទំនើបបំផុត នាពេលនេះសម្រាប់លក់នៅអឺរ៉ុប អាស៊ី ប៉ុន្តែមិនទាន់មកដល់អាមេរិកទេ ពីព្រោះអាមេរិកកំពុងពិសោធន៍ផលិតផលចេញពី ៥អ នេះ១០០ដងលើសចិនទៅទៀត គឺនៅចុងឆ្នាំ២០២០នេះ នៅអាមេរិក នឹងមានទូរស័ព្ទនឹងប្រព័ន្ធអិន្ទ័រណេតថ្មី ទូរទស្សន៍ប្រព័ន្ធថ្មី, មានរថយន្តឥតមានអ្នកបើកបរថ្មីនៅលើផ្លូវ, នឹងមានរថយន្តក្រុង"ប៊ីស" រថភ្លើងយន្តហោះប្រើប្រព័ន្ធថ្មីទាំងអស់, សន្តិសុខរបស់ប្រទេសក៏រងការផ្លាស់ប្តូរជាចាំបាច់, ប្រព័ន្ធព្យាបាលសុខភាពក៏ត្រូវប្តូរ, ប្រព័ន្ធលក់ដូរទំនិញ ក៏បានត្រៀមខ្លួនសម្រាប់រកស៊ីបែបថ្មីហើយដែរ...








ប្រជាពលរដ្ឋអាមេរិកាំងមិនទាន់បានត្រៀមខ្លួនទេដឹង? ការប្រែប្រួលគឺសំដៅទៅលើគុណភាព តែពុំមែននៅលើតម្លៃទំនិញទេ យើងបានឃើញហើយថា"ទិញទំនិញតាមអនឡាញ វាថោកជាងទិញនៅក្នុងហាង"នេះជាការត្រៀមខ្លួនទី១, សេវាជាច្រើននឹងចុះថោក ដោយសារអគ្គីសនីនឹងចុះថោកប្រេងឥន្ធនៈក៏នឹងត្រូវប្រើតិច នេះជាការត្រៀមខ្លួនទី២,សេវាដឹកជញ្ជូនក៏ចុះតម្លៃជាការត្រៀមខ្លួនទី៣,...។ រដ្ឋាភិបាលបានផ្តល់ប្រាក់ជំនួយ Pandemic ជាច្រើនពាន់ដល់ពលរដ្ឋអាមេរិកាំង ដល់អ្នករកស៊ីនឹងឯកជនសម្រាប់ទប់ទល់ការរាតត្បាតនៃកូវីដ១៩ លុយនោះនឹងនៅសល់ទំនងជាសម្រាប់ជោគជ័យនៃការផ្លាស់ប្តូរចម្បងនោះហើយ។

២-សេដ្ឋកិច្ច ក៏ប្តូរទីសដៅថ្មីសម្រាប់សករាជ្យ "៥អ" ដែលប្រទេសនិមួយៗកំពុងត្រៀមខ្លួន ទទួលយកទិសដៅថ្មីនោះ ដែលវានឹងប្តូរមុខមាត់របស់ប្រទេសទាំងមូលតែម្តង ដូចគ្នានឹងការរកឃើញប្រេងសាំង រកឃើញអគ្គីសនីរកឃើញប្រព័ន្ធកុំព្យូទ័រដែរ -ទាំងនោះសុទ្ធតែបានមនុស្សក្នុងពិភពលោកឱ្យរស់នៅស្រួលជាងមុនលឿនជាងមុនឆ្ងាយជាងមុនគ្រប់គ្រាន់ជាងមុនជាពិសេសមានកម្លាំងជាងមុន -សេដ្ឋកិច្ចពិភពលោកក៏សម្របទៅតាមជំនាន់ ៤អ យ៉ាងនោះទៅ។ តទៅទំព័រទី ១៣



តមកពីទំព័រទី ០៧

# កូវីដ១៩បានផ្ទុះឡើង...

សហគមន៍ដែលក្រីក្រមិនសូវមានចំណេះដឹង, សហគមន៍ដែលរស់នៅផ្ទះសម្បែងទីចង្អៀត ចង្អល់, តច្ចេលចិត្តការនៅជួបជុំគ្នា, ពុំមានការពិគ្រោះ ដើម្បីប្រុងប្រយ័ត្នការរាតត្បាតនៃជម្ងឺដ៏កាចសាហាវនោះទេ។ សហគមន៍ខ្មែរនៅឡូវែល ស្ងប់ស្ងាត់មិនចេញក្រៅផ្ទះច្រើនទេ ហាក់ដូចជា មកដល់ឱកាសពុំមានឆ្លងជម្ងឺរាតត្បាលនេះទេ ជាញយ១ គេឃើញសេចក្ដីរាយការថា"មនុស្សស្លាប់: ០"។



Coronavirus Cases:

13,241,632

view by country

Deaths:

575,641

Recovered:

7,708,047

| ACTIVE CASES | |
|---|---|
| 4,957,944 | |
| Currently Infected Patients | |
| 4,898,726 (99%) in Mild Condition | 59,218 (1%) Serious or Critical |
| Show Graph | |

| CLOSED CASES | |
|---|---|
| 8,283,688 | |
| Cases which had an outcome: | |
| 7,708,047 (93%) Recovered / Discharged | 575,641 (7%) Deaths |
| Show Graph | |










S W H

Senior Whole Health.
A MAGELLAN COMPANY

គម្រោងថែទាំសុខភាពសម្រាប់មនុស្សចាស់ជាមួយនឹងកម្មវិធី MassHealth ។

យើងនិយាយជាភាសារបស់អ្នក

យើងនិយាយបានជាង 40 ភាសា ហើយយើងនឹងជួយអ្នកឲ្យទទួលបានការថែទាំពីគ្រូពេទ្យដែលយល់អំពីអ្នក!

ស្វែងយល់បន្ថែម។ ហៅទូរស័ព្ទមក 1-888-566-3526 (TTY 711)។
www.seniorwholehealth.com

កម្មវិធី Senior Whole Health គោរពតាមច្បាប់ស្តីពីសិទ្ធិពលរដ្ឋសហព័ន្ធដែលចូលជាធរមាន និងមិនធ្វើការរើសអើងដោយសារពូជសាសន៍ ពណ៌សម្បុរ ដើមកំណើតជាតិ សាសន៍ អាយុ ពិការភាព ឬភេទឡើយ។ កម្មវិធី Senior Whole Health (HMO SNP) និង Senior Whole Health NHC (HMO SNP) គឺជាផែនការថែទាំសម្របសម្រួលដែលមានកិច្ចសន្យា Medicare Advantage និងកិច្ចសន្យាជាមួយសហធនរដ្ឋ Massachusetts /កម្មវិធី EOHHS MassHealth។ ការចុះឈ្មោះអាស្រ័យលើការបន្តកិច្ចសន្យារាល់ឆ្នាំ។
H2224-2020-84533 _M KHM Approved 2/11/2020

# “ក្រនឹងមាន”នៅកម្ពុជា

ដោយ អាសេឡិក

អ្នកមានលុយ“មីលីណែរ”ដោយចៃដន្យ

នៅឆ្នាំមុននេះសោះ កម្ពុជានៅមានសំណាងដ៏អស្ចារ្យដោយកំពុងតែត្រូវប៉ាន់ ដោយសេដ្ឋកិច្ចកំពុងរងនូវការហូរចូលនៃរូបិយប័ណ្ណមកពីប្រទេសចិនយ៉ាងគំហុកធ្វើឱ្យប្រជាពលរដ្ឋថ្នាក់លើមានមន្ត្រីធំៗ អ្នករត់ការពាណិជ្ជកម្ម អ្នករកស៊ីខ្នាតធំ អាចលក់ដូរដីឬជួលផ្ទះ ឬសង់អាគារខ្ពស់អេះមេឃបានចំណេញខ្ពស់កប់ពពក។ មន្ត្រីថ្នាក់ខ្ពស់មួយចំនួន គ្រាន់តែរត់ការរត់ក្រដាសស្នាមមធ្យមខ្លះ ក៏រកកម្រៃជើងសារសោះ ក៏បានប្រាក់ចំណូលក្រាស់ក្រែលដែរ។ គេថាមនុស្សម្នាក់ដែលមាន “សំណាង”មួយ នាឱកាសមួយ ហើយរួមទាំងមាន“ជំនាញខាងសេដ្ឋកិច្ច”មួយទៀតផងនោះ អាចបង្កើតជាសម្បត្តិមហាសាលមួយបានសម្រាប់ទ្រទ្រង់ជីវិត ។

ដូចជានៅពេលនេះ ប្រជាជនចិនដ៏មានចំនួនច្រើន បានចូលមកដល់កម្ពុជា នា១០ឆ្នាំចុងក្រោយនេះ នាំទាំងលុយហូរហៀរមកចាយជាវិនិយោគយ៉ាងខ្ជះខ្ជាយលុយនោះក៏បានក្លាយជាឱកាស ដល់ប្រជាពលរដ្ឋដែលរស់នៅស្រុកខ្មែរ ហើយក៏ជាប្រយោជន៍ដល់អ្នកដែលមានសំណាងបូកគ្នានឹងជំនាញខាងសេដ្ឋកិច្ចនោះភ្លាម។ ក្នុងរយៈពេលយ៉ាងខ្លីប៉ុណ្ណោះ សម្បត្តិក៏ពូនជាឡើងជាភ្នំចាយមិនអស់មិនថា ប្រាក់


សេដ្ឋកិច្ចក្រុងភ្នំពេញរងចាំស្ថេរភាពនៃច្បាប់

ចំណូលនោះបានមកដោយធមិ ឬក៏ដោយស្មោកគ្រោកនោះទេ,ចំនួនអ្នកមានដែលហៅថា“មីលីណែរ”ក៏ក្លាយជាសម្បូរពេលនោះថ្នាក់ដឹកនាំគេឈប់និយាយពីយុត្តិធមិ ឬក៏សុច្ចរិតអ្វីតទៅទៀតហើយ ពីព្រោះវាជាការប្រយុទ្ធជាការដណ្តើមហើយត្រូវមានចង្កូមវែងផង។

ឥឡូវប្រជាជនចិនទាំងឡាយនោះ បានត្រឡប់ទៅប្រទេសគេវិញ ឬក៏រលាយទៅណាបាត់អស់ទុកសំណល់វិនិយោគមិនដំណើរការរាប់មិនអស់, ជាមួយគ្នានោះ វានៅសល់តែអ្នកក្នុងស្រុក ដែលស្វែងរក“មានសំណាង”ក្រោយគេមានតែភ្នែកសំរាប់តែយំប៉ុណ្ណោះឯង ពីព្រោះចង់ធ្វើតាមអ្នកដែលគេរកស៊ីបានពីមុនៗ តែខ្វះជំនាញសេដ្ឋកិច្ចសម្រាប់ពិចារណាឱ្យបានវែងឆ្ងាយ ក៏លង់ទៅក្នុងចំណង់ជា“អ្នកមាន”នឹងគេបែរជាវណ្ឌករដោយប្រាក់វិនិយោគ ដ៏ងាយស្រួលនោះ វាលែងហូរធ្លាក់មកទៀតហើយ។ គេឃើញអ្នករកស៊ីខាងសណ្ឋាគារខាងលក់ដូរឱ្យទេសចរចិន, អ្នកវិនិយោគលើផ្ទះជួល, អ្នកទិញ ឬលក់ដីធ្លី... គេកំពុងគាំងដំណើរ កកលុយ សល់តែទឹកភ្នែក។

អ្នកមានលុយ“មីលីណែរ”ដោយព្យាយាម

បើលោកអ្នកជាអ្នកធ្វើការបើកប្រាក់ខែទៀងទាត់ ក៏នៅមានវិធីដែលអ្នកអាចក្លាយជា“មីលីណែរ”ផ្សេងទៀតបានដែរ។ គឺត្រូវតែមានការព្យាយាមសន្សំប្រាក់ទុកដាក់ផ្សេងមួយចំនួនឱ្យធ្វើឱ្យទៅជាដើមទុនអាចឱ្យលុយនោះធ្វើការផលិតប្រាក់ចំណូលជំនួសកម្លាំងមនុស្សបាន ។ សង្គមអាមេរិកាំងជាសង្គមគោរពច្បាប់ គេសន្សំលុយរហូតដល់“ក្តីស្រម័យរបស់គេ ក្លាយទៅជាការពិតបាន” ហើយពលរដ្ឋអាមេរិកាំង ទោះធ្វើការតូចតាច ក៏ចាស់ទៅមិនពឹងពាក់ឱ្យកូនចៅចិញ្ចឹមទេ ថែមទាំងមានប្រាក់សន្សំដែលបានកើន ជាលុយវាល់លាន ទុកឱ្យកូនចៅគេបានទៀតផង, ទាំងនោះ គឺប្រព្រឹត្តទៅដោយមិនចាំបាច់ប្រឹងមិនចាំបាច់លួចប្លន់នរណាមិនចាំបានមានចង្កូមវែងនោះទេ តែអ្នកត្រូវខិតខំធ្វើការតាំងពិនៅវ័យក្មេងកុំចាំដល់ចាស់ទើបចាប់ច្រវាចែវទូកនៃជីវិតខ្លួន ពេលនោះវាយឺតពេលហើយ ។

តទៅទំព័រទី១៣

# អស់បារម្ភជាមួយបញ្ហាថ្នក់ក្រោមភ្នែកជាមួយនឹងវិធីងាយៗទាំងនេះ!

មុខ គឺជារឿងសំខាន់មួយសម្រាប់សម្រស់ខាងក្រៅ ព្រោះថា តែកាលណាមុខរបស់យើងមានផ្នែកណាមួយមិនស្អាតហើយនោះ វានឹងធ្វើអោយយើងមិនសូវមានទំនុកចិត្ត រីសប្បាយចិត្តនឹងខ្លួនឯង។ ក្នុងចំនោមបញ្ហានៅលើផ្ទៃមុខជាច្រើន បញ្ហាស្នាមដក់នៅក្រោមភ្នែកគឺជាបញ្ហាដែលមនុស្សជាច្រើនកំពុងតែជួបប្រទះដូចៗគ្នា។

សម្រាប់អ្នកមានបញ្ហាដូចនេះ ក្រៅពីការទៅវះកាត់បូមបូមយកខ្លាញ់ដែលនៅក្រោមភ្នែកនោះចេញ យើងមានវិធីងាយៗមួយចំនួនទៀតដែលអ្នកអាចធ្វើបាន ដោយគ្រាន់តែវាត្រូវចំនាយពេលរាងយូរបន្តិច។

## វិធីទាំងនោះមានដូចជា:

### ១. ដំឡូងបារាំង

អត្ថប្រយោជន៍ដំឡូងបារាំងចំពោះសម្រស់គឺមិនចេះរីងស្ងួត។ដូចគ្នាអញ្ចឹងដែរ ដើម្បីដោះស្រាយបញ្ហាថ្នក់ក្រោមភ្នែក អ្នកអាចយកដំឡូងបារាំងឆៅមួយមកពុះជាពីរចំនិច ហើយញីវា



ថ្នមៗនៅជុំវិញភ្នែកនោះ។ បន្ទាប់មកទៀតដាក់វាទុកចោលប្រមាណជា២០នាទី សឹមលាងវាចេញជាការស្រេច។ ធ្វើបែបនេះ២ទៅ៣ដងនៅក្នុងមួយអាទិត្យដើម្បីទទួលបានលទ្ធផលឆាប់រហ័ស។

### ២. ទឹកដោះគោ

វិធីមួយទៀតនៅក្នុងការដោះស្រាយបញ្ហានេះគឺយកសំឡីកប្បាសមកច្រលក់វាអោយជោគល្មមនៅក្នុងទឹកដោះគោឆៅ រួចស្អំនៅលើភ្នែកប្រមាណ២០នាទីទៅ ៣០នាទីសឹមលាង



វាចេញ។

### ៣. ត្រសក់

សម្រាប់បញ្ហារង្វង់ភ្នែកខ្មៅ រឺស្នាមថ្នក់ក្រោមភ្នែកជាដើមការប្រើប្រាស់ត្រសក់មក



ព្យាបាលគឺជាវិធីដ៏មានប្រសិទ្ធិភាពបំផុត។ អ្នកអាចយកត្រសក់ពីរចំនិតមកដាក់ស្អំលើផ្នែកប្រមាណ២៥នាទី ហើយសឹមលាងជម្រះវាចេញ។

### ៤. កាកតែ

តើអ្នកដឹងទេថា បន្ទាប់ឆុងតែរួច កាកតែនោះគឺមានប្រសិទ្ធិភាពខ្លាំងណាស់នៅក្នុងការ



ដោះស្រាយបញ្ហានេះ។ អ្នកគ្រាន់តែយកកាកកែចំនួនពីរថង់តូចៗមកស្អំលើភ្នែកប្រមាណ២០នាទីជាការស្រេច។

### ៥. ពងមាន់ផ្នែកស

វិធីម្យ៉ាងទៀតនៅក្នុងការព្យាបាលបញ្ហានេះគឺប្រើប្រាស់ពងមាន់ផ្នែកខាងស។ អ្នកអាច



យកពងមាន់ផ្នែកខាងសមកលាបនៅលើកន្លែងដែលមានថ្នក់ទុកចោលប្រហែលជា២០នាទី។ បន្ទាប់មកអ្នកអាចលាងសម្អាតវាជាមួយនឹងទឹកត្រជាក់ជាការស្រេច។

តមកពីទំព័រទី ០៦

# តំបន់អភិរក្សសត្វស្លាប និងព្រៃលិចទឹក

វិទ្យាសាស្ត្រអេកូទេសចរណ៍ និងជាទីពិសោធន៍ជីវចំរុះរបស់ខេត្តត្បូងឃ្មុំសំរាប់កូនខ្មែរជំនាន់ក្រោយៗទៀតផងដែរ។

បន្ទាប់មកបានបន្តដំណើរចុះពិនិត្យទីតាំងច្រាំងបាក់ (នៅខាងក្រោយគេហដ្ឋានសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន) គឺស្ថិតនៅភូមិទី២ ឃុំរកាខ្នុរ ស្រុកក្រូចឆ្មារ មានប្រវែង៥០០ម៉ែត្រ និងទីតាំងបាក់ច្រាំងមួយកន្លែងទៀត



ស្ថិតនៅវត្តហ្លួង (ហៅវត្តកណ្តាល) មានប្រវែង៤០០ម៉ែត្រ ដែលឥឡូវនេះ មន្ទីរធនធានទឹក និងឧតុនិយម ខេត្តត្បូងឃ្មុំ កំពុងបូមខ្សាច់ដាក់បាវអាចរក្សាបានរហូត៦០ឆ្នាំទើបពុកផុយ ដើម្បីទប់ច្រាំងកុំឱ្យបាក់បន្តទៀត។

បើតាមលោក សយ ទូច អភិបាលស្រុក បានឱ្យដឹងថា ការដ្ឋានសាងសង់ទំនប់បង្វៀរទឹកព្រែកតាកុច និងបឹងកណ្តោរ គឺជាប្រភពទឹកផង និងជាកន្លែងផ្តល់ជម្រកត្រីផងដែរ ពិសេសសម្រាប់ប្រជាកសិករច្រើនជាង៤០០០គ្រួសារ ប្រើប្រាស់ទឹកក្នុងការធ្វើស្រែចំការ ដោយមានវិសាលភាពស្រោចស្រពស្រែច្រើនជាង១ម៉ឺនហិចតានៅជុំវិញតំបន់នោះ ដែលទីតាំងទាំងនេះស្ថិតនៅក្នុងឃុំរការខ្នុរ និង ឃុំឈ្យូក ក្នុងភូមិសាស្ត្រស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។

ក្រុមហ៊ុនអចលនៈទ្រព្យ អឺប៊ឺន រាលអ៊ីស្តេត
URBAN REAL ESTATE
មជ្ឈមណ្ឌលផ្តល់សេវាជួលលំនៅដ្ឋាន
Residential Leasing Center



ដានៀល តាន
ភ្នាក់ងារអចលនៈទ្រព្យ
Daniel Tan
Real Estate Agent
Cell: 978-902-6354
508 Westford Street • Lowell, MA 01851
(978) 454-0444

ក្រុមហ៊ុនធានារ៉ាប់រង ខេខេ អ៊ីនស្ចូរិន អេជេនស៊ី
KK Insurance Agency, Inc.
រថយន្ត • លំនៅដ្ឋាន • អាជីវកម្ម
Car • Home • Business
508 Westford Street
Lowell, MA 01851
978-970-2212
kk@kkinsurancema.com



ការិយាល័យច្បាប់
រ៉ូសា និង តាំង



Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ស៊ីស្កូ ជេ.រ៉ូសា



Andrew ´Bunna´ Taing, Esq.
មេធាវី អែនឌ្រូវប៊ុណ្ណា តាំង
Law Office of
Rosa & Taing
ATTORNEY AT LAW

SERVICES
- Auto Accidents/ Personal Injury
- Bankruptcy
- Immigration
- Consumer Protection
- Real Estate Closings/Disputes
- Divorces Child Custody

តំណាងក្តីដូចខាងក្រោម
- គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ
- ក្ស័យធន
- អន្តោប្រវេសន៍
- ការពារអតិថិជន
- ទំនាស់ផ្ទេរអចលនវត្ថុ
- លែងលះ និងអាណាព្យាបាលកិច្ច

1550 Middlesex Street Lowell, MA 01851
Phone: 978-458-0934 | at@rosataing.com



CONWAY
INSURANCE AGENCY
រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវ៉េយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។
យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បៈ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- កម្មករ (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការរស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY
INSURANCE AGENCY
77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

# កម្មវិធីផ្តល់ជូនអាហារ សម្រាប់រដូវក្តៅ

## មិនគិតថ្លៃដល់កុមារ និងយុវជន

Merrimack Valley Food Bank, Inc.
Feeding Families Since 1991
Est. 1991

**ខែកក្កដា ទី 6 - សីហា ទី 14, 2020!!**

**ទូរស័ព្ទលេខ:**
**1-800-645-8333**

**ផ្ញើសារ**
**"Food" រឺ "COMIDA" ផ្ញើទៅកាន់ 877-877**

**វិបសាយ**
**WWW.MEALS4KIDS.ORG**

**ដោនឡូតអាប់**
**"SUMMEREATS" សម្រាប់**
**IPHONE និង ANDROID**

កម្មវិធីផ្តល់ជូនអាហារសម្រាប់រដូវក្តៅមិនគិតថ្លៃដល់កុមារ និងយុវជនអាយុ 18 ឆ្នាំ និងមានអាយុក្រោមនេះ។ មិនត្រូវការចុះឈ្មោះ រឺ ចាំបាច់មាន I.D នោះទេ។ អង្គការនេះ គឺផ្តល់ឱកាសស្មើគ្នា។

ទីតាំងក្នុងការផ្តល់អាហារមានដូចខាងក្រោម!!

ផ្លូវ Caleb Group 77 Chestnut St.
(អាហារថ្ងៃត្រង់) 11:15 - 12:00
(អាហារសំរន់) 2:15-2:35 ថ្ងៃច័ន្ទ- សុក្រ

ផ្លូវ Eagle Park 95 W. 6th St.
(អាហារថ្ងៃត្រង់) 11:15-11:45 ថ្ងៃច័ន្ទ- សុក្រ

McPherson Pool 1000 Bridge St.
(អាហារថ្ងៃត្រង់) 12:15 -1:00 ថ្ងៃច័ន្ទ- សុក្រ

ផ្លូវ North Canal Apartments 517 Moody St.
(អាហារថ្ងៃត្រង់) 12:15 -12:45 ថ្ងៃអង្គារ-ព្រហស្បត្តិ៍

ផ្លូវ O'Donnell Splash Pad 1170 Gorham St.
(អាហារថ្ងៃត្រង់) 1:30 -2:00 Mon -Fri

PROJECT BREAD A FRESH APPROACH TO ENDING HUNGER
CNOP CHILD NUTRITION OUTREACH PROGRAM
MASSACHUSETTS DEPARTMENT OF ELEMENTARY AND SECONDARY EDUCATION

KhmerPost USA, LLC

សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក





អគ្គនាយក សុបិន្ត ពិន

Soben Pin, Co-Founder|Publisher

Office: 978 677-7163 | Cell: 978-656-8141

Soben@khmerpostusa.com





និពន្ធនាយកខ្មែរ Khmer Editorial

និពន្ធនាយក ពិន សំខុន

Roger Samkhon Pin, Co-founder|Editor

978-942-8490 | pinsamkhon@gmail.com

ផ្សាយពាណិជ្ជកម្ម សុបិន្ត ពិន

Advertising Contact

Soben Pin

Cell: 979-656-8141

Soben@khmerpostusa.com

អ្នកនិពន្ធកិត្តិយស Staff Writer| Translator

Sokharath Koy | Khmerpostusa@gmail.com

ច្នៃសោភ័ណ្ឌភាព Design Artist

Heng Chhun Leng



The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.

Follow us: Facebook | Twitter KhmerpostUSA



## សមាគម"អាសេឡិច"មានអ្នកជួយធ្វើសំណុំរឿងជួយដល់អ្នកអត់ការធ្វើ

-ពាណិជ្ជករចង់បានប្រាក់ជំនួយជាប្រាក់កម្ចីរបស់រដ្ឋ និងជួយដល់អ្នកដែលមិនបានទទួលស្ទីមេលីស និងឯកសាររដ្ឋបាលផ្សេងៗទៀត ។

-មានសេវាផ្សេងទៀត ដូចជាៈ ផ្ទាក់យកប័ណ្ណបើកបររថយន្ត ផ្ទាក់បង្រៀនយកសញ្ជាតិអាមេរិកាំង មានសេវាសុំប័ណ្ណបើកម្ហូបអាហារ

-មានសេវាអន្តោប្រវេសន៏ទៀតផង

សូមទូរស័ព្ទមកសមាគម "អាសេឡិច" ទូរស័ព្ទលេខ 978-942-8490

អាស័យដ្ឋានលេខ: 325 Chelmford St. Lowell

## ការិយាល័យ មេធាវី ចំមាស ស្តាលីយ៉ាណូស

Law Office of Thomas Stylianos Jr.

287 Appleton St. Lowell MA 01852

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766

www.thomasinlowell.com


តមកពីទំព័រទី ១០

## ក្រ និងមាននៅកម្ពុជា...

បើអ្នកព្យាយាមអ្នកផ្តោតអារម្មណ៍លើការថែរទាំទ្រព្យសម្បត្តិដែលរកបាន,សិក្សាពីដំណើរច្បាប់ដែលបើកឱ្យយើងរីកចំរើនរដ្ឋនឹងធានាឱ្យសម្បត្តិហូរតក់ៗចូលក្នុងហោប៉ៅយើងយ៉ាងទៀងទាត់ ដោយមិនភ័យព្រួយពីការឈឺថ្កាត់,មិនភ័យព្រួយពីពិការភាព,មិនភ័យព្រួយពីកូនចៅធំធាត់ចេញទៅទុកឱ្យពុកម៉ែនៅតែឯកឯងទេ។ នៅស្រុកខ្មែរច្បាប់មិនរឹងមាំតុលាការមិនកាពារអ្នកក្រីក្រទេ ដូច្នេះនឹងមានការលំបាកនឹងទៅដល់គោលដៅតែមិនមែនថា ធ្វើមិនបាននោះ ទេ។

បើចង់ដឹងពីវិធីលំអិតជាងនេះសូមទូរស័ព្ទទៅ អេសេឡិក ៩៧៨-៩៤២ ៨៤៩០



តមកពីទំព័រទី ០៨

## ថ្មីត្បិត"កូវីត១៩"សាហាវ តែពិភពលោក

ប៉ុន្តែឥឡូវថា"ជំនាន់៥អ" វាមានថាមពលនឹងឥទ្ធិពលច្រើនរយដងជាងមុន តើយើងជាមនុស្សធម្មតា តើអាចទាយត្រូវទេថា "ពិភពលោកថ្មីយើង"នេះ នឹងប្រែប្រួលទៅជាយ៉ាងណា ?

គិតសាជាថ្មីទៅ គឺទំនងជាត្រូវប្តូរសម្ភារថ្មីហើយៈ មែនហើយ! សម្ភារៈដែលចាំបាច់ហើយ ជឿនលឿនពីឆ្នាំមុន ប្រហែលជាត្រូវបោះចោលទាំងអស់ហើយពីព្រោះថា"វត្ថុប្រើប្រាស់ទាំងអស់ ដែលហៅថាទំនើបនោះ សុទ្ធតែមនុស្សបញ្ជាឱ្យកុំព្យូទ័រធ្វើ ប៉ុន្តែចាប់ពីស្អែកនេះតទៅពុំមែនមនុស្សបញ្ជាកុំព្យូទ័រទៀតទេ គឺ"កុំព្យូទ័រជំនាន់ទី៥ ៥អ វានឹងចេញបញ្ជាទៅហ្វូងកុំព្យូទ័រគ្នាវា"សម្រាប់បំរើមនុស្សយើងៈ

១-ទូរស័ព្ទដៃៈ យើងធ្លាប់តែទៅទិញ"វ៉ាយហ្វាយ"ណាដែលខ្លាំងជាងគេសម្រាប់ដាក់ក្នុងទូរស័ព្ទ តែឆ្នាំក្រោយ"វ៉ាយហ្វាយ"ដែលខ្លាំងជាងមុន១០០ដងវាបុកចូលទូរស័ព្ទដៃយើងទៅវិញ ធ្វើឱ្យទូរស័ព្ទដៃចាស់សព្វថ្ងៃរបស់យើងប្រើមិនកើត ត្រូវតែប្តូរចោលយកអាថ្មីជំនួស ទើបអាចទទួលសេវាថ្មីបាន ហើយប្រសិទ្ធភាពថ្មីមិនធ្វើឱ្យយើងស្តាយក្រោយទេ។ ទូរទស្សន៏ដែលជាវត្ថុសំណប់ចិត្ត១ទៀត ដែលកំដរយើងពេលចប់ការងារ ពេលសម្រាកកាយ ក៏ដូចគ្នានឹងត្រូវផ្លាស់ប្តូរដោយគេប្រើបច្ចេកទេសកសាងវាចេញមកខុសស្រឡះពីពេលមុន ដែលនឹងប្រើសេវាថោកជាងលឿនជាង រូបភាពនឹងសម្លេងល្អជាងមុនច្រើនជាងមុន, វត្ថុសំណប់ចិត្តនោះ ក៏ត្រូវប្តូរចេញទាំងមិនដាច់ចិត្តដែរ។ យើងនៅមិនទាន់មើលឃើញនៅឡើយថា"តើទូរទស្សន៏ប្រើខ្សែភ្លើងនឹងទូរស័ព្ទនៅផ្ទះអាចមានជីវិតរស់បន្ត"របៀបណានៅឡើយទេ ទំនងជាត្រូវស្លាប់តែហោងផង ក៏មិនដឹង។

២-រថយន្តថ្មីទំនើបកាលពីឆ្នាំមុន មានសេវាបញ្ជាស្វ័យប្រវត្តិបន្តិចបន្តួច ដែលម្ចាស់រថយន្តនៅតែបញ្ជាដោយខ្លួនឯងតែដដែល ប៉ុន្តែរថយន្តឆ្នាំក្រោយ មានស្នាដៃបញ្ជាខ្លួនវាដោយមិនចាំបាច់អ្នកបើកបរទៀតឡើយ។ រថយន្តនោះវាមិនចេះបុកគ្នាទេ វាស្គាល់ផ្លូវរបស់អ្នកយ៉ាងច្បាស់ជាងខ្លួនអ្នកទៅទៀត, វាមិនឃ្លានសាំងច្រើនទេផ្ទុយទៅវិញ វានឹងប្រើថ្មអាគុយច្រើនទៅវិញ វានឹងចេះច្បាប់ចរាចរមើលផ្លូវឃើញបទបញ្ជានៅតាមផ្លូវសាធារណៈទាំងភ្នែកយើងមិនបានឃើញទៀតផង។ គេអាចនឹងទិញវាក្នុងតម្លៃដ៏ថ្លៃមួយ នាគ្រាដំបូង តែវានឹងចុះថោកយ៉ាងឆាប់រហ័ស ទាំងតម្លៃសេវា"ធានារ៉ាប់រង"ទាំងសេវា"ថែរទាំរាល់ថ្ងៃ", ហើយក៏អាចប្រើបានគ្រប់គ្នាទាំងមនុស្សចាស់មនុស្សពិការ អ្នកក្រឬមានផង។រថយន្តរបៀបនេះវានឹងលាតសន្ធឹងទៅសេវា"រថយន្តដឹកមនុស្សក្នុងក្រុង"មានប៊ីសឬតាក់ស៊ីជាដើម ដែលនឹងគ្មានមនុស្សជាអ្នកបើកបរ ហើយទទួលឬជូនអ្នកដំណើរដល់ផ្ទះផង។

លោកអ្នកមិនអស្ចារ្យទេ ឬចំពោះដំណឹងរបៀបនេះ? យើងនឹងបន្តរចក្ខុវិស័យនៅលេខបន្តបន្ទាប់ សម្រាប់លោកអ្នកក៏ត្រូវត្រៀមខ្លួនចូលសតវត្សជំនាន់ទី៥នេះដែរហើយ។

(នៅមានត)

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare

### Home Care Agency

Group Adults Foster Care Program

***ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុម គ្រួសារដែលបានរស់នៅ ជាមួយគ្នាជាយូរមកហើយ ។ សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។***

*At no Cost to you*

សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកដោយមិនគិតថ្លៃអ្នកនឹងត្រូវបានថែទាំដោយក្រុមបុគ្គលិក ខ្មែរដែលមានវិជ្ជាជីវៈពី នើស (Nurse), Case Manager និង Home Health Aide បុគ្គលិកមានសណ្តានចិត្តល្អ ទន់ភ្លន់ និងមានការគោរពទំនៀមទំលាប់ខ្មែរ ។ បំរើសេវាក្នុងតំបន់ Lowell, Lynn, Revere, Boston និងតំបន់ជុំវិញ





**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- *រស់នៅផ្ទះរដ្ឋ*
- *អាយុ ២២ ឆ្នាំឡើងទៅ*
- *មាសហ៊ែលស្តង់ដា*

**ផលប្រយោជន៍ទទួលបាន :**

- *ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយ ថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ*
- *ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក*
- *ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយ គ្រូពេទ្យ និងខេសម៉ានីជើ*
- *វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់*
- *សមាជិកអាចទាក់ទងមក២៤ម៉ោង*

**To be eligibled for GAFC you must:**

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

**Benefits you will get:**

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

## ដើម្បីចុះឈ្មោះសូមទាក់ទងមក

### To register, please contact:

Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

"អត្ថបទស្រាវជ្រាវប្រវត្តិសាស្ត្រ"

# ប្រវត្តិនៃសមាគមអ្នកសារព័ត៌មានខ្មែរ "ខេជីអេ"

## អវសានន្តនៃសមាគម KJA Khmer Journalists Association

(KJA = Khmer Journalist Association )

ដោយ ពិន សំខុន **តពីលេខមុន**

...យ៉ាងចាស់ ដៃតទល់គ្នានឹងអង្គភាពព័តិមានគណបក្សប្រជាជន ដែលមានប្រមាណជា១០០រាប់ទាំងអង្គភាពរដ្ឋផង ។ ទ្រង់ទ្រាយនៃប្រព័ន្ធគ្រប់គ្រងនយោបាយពេលនោះ គឺសម្ព័ន្ធភាពរវាងគណបក្សហ៊្វុនស៊ិនប៉ិចនឹងគណបក្សប្រជាជនកម្ពុជាកំពុងតែប្រេះឆាយ៉ាងចំហរ រីឯគណបក្សជាតិខ្មែរ ក៏កំពុងតែដុតបន្ថែមលើការបែកបាក់នេះ យ៉ាងចាស់ដៃដែរ ។

ថ្ងៃទី១៨ ឧសភា ១៩៩៦ អ្នកកាសែតមនសិការខ្មែរឈ្មោះ ធន់ ប៊ុនលី មាននិន្នាការខាងលោក សម រង្ស៊ី បានត្រូវជនជិះម៉ូតូ២នាក់ បាញ់ស្លាប់នៅមុខប៉ុស្តិ៍ប៉ូលិស ដោយរកឃាដករមិនឃើញ។ ប៊ុនលី មុននឹងស្លាប់បានទទួលការព្រមានផ្ទាល់មាត់ពី ពិន សំខុន នៅទីស្នាក់ការសមាគមមុនគេបាញ់១ថ្ងៃថា "កុំឱ្យប្រើពាក្យជេ ប្រមាថខ្លាំងៗលើភរិយាលោក ហ៊ុន សែន ដែលអាចនាំឱ្យគ្រោះថ្នាក់តែអត់ប្រយោជន៍។ នេះជាការធ្វើឃាដអ្នកកាសែតជាលើកទី៤ បន្ទាប់ពីមានការសម្លាប់ដោយបំផ្ទុះគ្រាប់បែកនៅទីស្នាក់ការវិទ្យុហ៊្វុនស៊ិនប៉ិចនៅប៉ុន្មានខែមុន បណ្តាលឱ្យស្លាប់អ្នកកាសែតម្នាកឈ្មោះ ឯក មង្គល ។



ឧត្តមសេនីយ៍ ញឹក ប៊ុនឆៃ តំណាងអោយហ៊្វុនស៊ិនប៉ិចជាអ្នកទាក់ទាញអោយក្រុមខ្មែរក្រហមចូលរួមសង្គ្រោះជាតិ

ទោះជាមានអសន្តិសុខក្តីសមាគមនៅតែទៅជួយលើកទឹកចិត្ត សមាជិកអ្នកសារព័តិមានយ៉ាងសកម្មដដែល ។ នៅពេលជាមួយគ្នានោះនាយកកាសែត យឹម រតនា បានត្រូវតុលាការបានត្រូវតុលាការខ្មែរ ដាក់ទោសជាប់គុក១ឆ្នាំ, ដោយសារអត្ថបទ "ប្រទេសខ្មែរជាស្រុកចោរ" ហើយក៏មាននាយកកាសែតម្នាក់ទៀត របស់ដំណឹងពេលព្រឹក គឺ នួន នន់ ក៏ត្រូវតុលាការដដែលដាក់គុក១ឆ្នាំដែរ ដោយសារអត្ថបទធ្វើឱ្យទាហ៊ានបះបោរ... នៅមានអ្នកកាសែតប្រឆាំងម្នាក់ទៀត ឈ្មោះ ហែម វិភាគ ក៏ត្រូវជាប់គុក១ឆ្នាំដែរ ដោយបុព្វហេតុប្រឆាំងនឹងរដ្ឋាភិបាលពុករលួយ... តែរៀងរាល់ពេលដែលមានអ្នកកាសែតរងគ្រោះដោយអយុត្តិធមិសមាគមតែងបានធ្វើសកម្មភាពការពារឱ្យមានការដោះលែងមកវិញក្នុងរយៈពេលតិចជាង១ខែ យ៉ាងជោគជ័យដោយការស្នើសុំព្រះមហាក្សត្រ សូមព្រះអង្គព្រះរាជទាន "ការលើកលែងទោស" នឹងបញ្ជូនព័តិមានទៅបណ្តាញព័តិមានអន្តរជាតិពីភាពអយុត្តិធមិចំបោះអ្នកកាសែត ដែលគ្រាន់តែបញ្ចេញមតិលើទំព័រកាសែត ។

នៅមានការគម្រាមកំហែងបែបផ្សេងទៀត ដោយកងប៉ូលិសលើកគ្នាពេញទាំងឡាន ទ្រុងបំរុងទៅកំទេចទីស្នាក់ការកាសែត ដែលសរសេរប៉ះពាក់មេ ឬក៏អង្គភាពសង្កាត់របស់ខ្លួន ។ អ្នកកាសែតទាំងនោះមិនបានឱបដៃឱ្យប៉ូលិសចូលមកកំទេចទីកន្លែងខ្លួននោះទេ, នៅទីស្នាក់ការកាសែតកោះសន្តិភាពនៅក្បែរស្តាតអូឡាំពិករបស់ ថុង អ៊ុយប៉ាង ដែលមាននិន្នាការខាងគណបក្សប្រជាជនទាំងបុគ្គលិកកាសែតទាំងប្រធានគេ បានកាន់កាំភ្លើងគ្រប់ដៃត្រៀមបាញ់ពីលើផ្ទះ៤ជាន់ រង់ចាំការមកដល់នៃកងប៉ូលិសប្រដាប់អាវុធ...។ នៅទីស្នាក់ការកាសែតយុវជនវិញ ក៏ដូចគ្នានាយក អ៊ូ សុវណ្ណ និន្នាការខាងគណបក្សជាតិខ្មែរក៏កាន់កាំភ្លើងតែម្នាក់ឯងនៅពីក្រោយរបាំងបារ៉ដីខ្សាច់ប្រថុយជីវិតទប់ទល់យកស្លាប់រស់តទល់នឹងកងប៉ូលិសចល័ត ដែលទំនងជាចង់មកកំទេចទីស្នាក់ការរបស់គេដែរ... តែប្រធានសមាគម ពិន សំខុន ទទួលដំណឹងភ្លាមឱ្យដំណឹងតាម "អាយកូម" ក៏ប្រញាប់ទៅជួយ

តទៅលេខក្រោយ







# សូមបំពេញជំរឿនឆ្នាំ-2020 សម្រាប់សហគមន៍របស់យើង។



ជំរឿនឆ្នាំ 2020 គឺដើម្បីធ្វើការរាប់ចំនួនប្រជាពលរដ្ឋគ្រប់ៗរូប ដែលរស់នៅក្នុងសហរដ្ឋអាមេរិក។ សូមជួយបំពេញជំរឿននៅថ្ងៃនេះ ដើម្បីទទួលបានសេចក្តីជូនដំណឹងអំពីជំនួយរាប់ពាន់លានដុល្លារអាមេរិក នឹងជួយដល់គ្លីនិកសុខភាព សេវាសង្គ្រោះបន្ទាន់ និងវិស័យអប់រំជារៀងរាល់ឆ្នាំ សម្រាប់រយៈពេលដប់ឆ្នាំខាងមុខទៀតនេះ។

**សូមបំពេញជំរឿនតាមអនឡាញ ឬ តាមប្រអប់សំបុត្រ។ ដើម្បីស្វែងយល់ពីរបៀបបំពេញសូមមើលគេហទំព័រនេះ 2020CENSUS.GOV/km**

**2020CENSUS.GOV/km**

ឧបត្ថម្ភដោយ ក្រសួងជំរឿនប្រជាជនសហរដ្ឋអាមេរិក (U.S. Census Bureau)

**Shape your future START HERE >**

United States® Census 2020